**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.)

## ECONOMIC, SOCIAL AND CULTURAL COUNCIL (ECOSOCC)



សម្តេចធិបតី ហ៊ុន ម៉ាណែត៖ កំពង់ផែពហុបំណងកំពត នឹងក្លាយជាកំពង់ផែទឹកជ្រៅ និងទំនើបនៅកម្ពុជា







# របាយការណ៍វិភាគស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ប្រចាំឆ្នាំ២០២៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**លេខៈ** ......................១៤ របក...................... **ក.ស.វ.**

ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំម្សាញ់ សប្ដស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៥

# របាយការណ៍
# ស្តីពី
# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថានកម្ពុជា ប្រចាំឆ្នាំ២០២៤*

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) បានធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថានរបស់កម្ពុជាប្រចាំឆ្នាំ២០២៤ ដោយផ្អែកលើទិន្នន័យព័ត៌មាន ដែលទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ដែលជាធាតុចូលពីកិច្ចប្រជុំទូលាយរបស់ក.ស.វ. ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងកិច្ចប្រជុំចង្អៀតផ្សេងទៀតរបស់ក.វ.ស. ដោយឈរលើគោលការណ៍បរិយាបន្ននៃសេចក្តីវិនិច្ឆ័យ ដែលមានខ្លឹមសារ ដូចខាងក្រោម៖

## I. បម្រែបម្រួលគួរឱ្យចាប់អារម្មណ៍

ក្នុងឆ្នាំ២០២៤នេះ សូចនាករសេដ្ឋកិច្ចមួយចំនួន បង្ហាញបម្រែបម្រួលគួរឱ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | %Δ ធៀបនឹងឆ្នាំ ២០២៣ | ផ្សេងៗ |
|---|---|---|
| ១) ថ្លៃបន្លែ | ៤,៥% | តារាងទី ១ |
| ២) ថ្លៃផ្លែឈើ | ២,៦% | តារាងទី ១ |
| ៣) ថ្លៃប្រេងសាំង | –៦,៣% | តារាងទី ១ |
| ៤) ថ្លៃប្រេងម៉ាស៊ូត | –៧,៧% | តារាងទី ១ |
| ៥) ចំណូលថវិកាជាតិ | –៣,១% | តារាងទី ២ |
| ៦) ចំណូលពន្ធដារ | –៤,៩% | តារាងទី ២ |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្ដប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរនិងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឱ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឱ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | |
|---|---|---|
| ៧) ចំណូលពីអដ្ឋាបណ្ណក្នុងស្រុក | –២៣,០% | តារាងទី ២ |
| ៨) ចំណាយថវិការជាតិ | –៧.០% | តារាងទី ២ |
| ៩) អ្នកចុះឈ្មោះស្វែងរកការងារ | ៦៣,៩% | តារាងទី ៤ |
| ១០) អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | –១៦,១% | តារាងទី ៤ |
| *បានការងារក្នុងប្រទេស* | –១៤,៤% | តារាងទី ៤ |
| *បានការងារក្រៅប្រទេស* | –២៥,៨% | តារាងទី ៤ |
| ១១) ការនាំចេញកៅស៊ូ | –១០,៩% | តារាងទី ៥ |

## II. ឧបសម្ព័ន្ធ

### ក. ការពិពណ៌នាទិន្នន័យតារាង

#### ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់ (តារាង១)

អតិផរណាឆ្នាំ២០២៤ មានអត្រាស្មើនឹង ០,៨% ក្នុងនោះក្រុមទំនិញទាំង១២ មានអត្រាអតិផរណាផ្សេងគ្នា ដូចក្នុងតារាងខាងក្រោម (សម្រាប់ឆ្នាំ ២០២៤ និងឆ្នាំ២០២៣)។

តារាង ១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញ

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ២០២៤, % | អតិផរណាឆ្នាំ២០២៣, % |
|---|---|---|---|
| | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ០,៨ | ២,១ |
| ១ | សម្លៀកបំពាក់ និងស្បែកជើង | ២,៨ | ៣,១ |
| ២ | ការសិក្សា | ២,៥ | ១,៧ |
| ៣ | សុខាភិបាល | ១,៦ | ០,៣ |
| ៤ | ម្ហូបអាហារ | ១,២ | ៣,៣ |
| ៥ | គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ០,៨ | ១,៤ |
| ៦ | ទំនិញនិងសេវាកម្មផ្សេងៗ | ០,៧ | ២,២ |
| ៧ | ការកម្សាន្ត និងវប្បធម៌ | ០,៤ | ៣,១ |
| ៨ | ភោជនីយដ្ឋាន | ០,៣ | ២,០ |
| ៩ | លំនៅឋាន ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងៗ | ០,២ | ០,៤ |
| ១០ | ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | -០,១ | ២,៤ |
| ១១ | ទូរគមនាគមន៍ | -០,១ | ០,១ |
| ១២ | ដឹកជញ្ជូន | -១,៣ | -២,១ |
| | ក្នុងនោះប្រេងសាំង | -៦,៣ | -៦,៧ |

គួរកត់សម្គាល់មុខទំនិញដែលឡើងថ្លៃខ្ពស់ គឺបន្លែ ៤,៥% និងផ្លែឈើ ២,៦%។

តារាង១.២. អតិផរណាប្រចាំខែ ឆ្នាំ២០២២-២០២៤ (កំណើនថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន)

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២៤ | ដូចគ្នាឆ្នាំមុន | -២,៥% | ០,៧% | ០,២% | ០,៥% | ០,៨% | ០,៧% | ០,៦% | ០,៣% | ០,៨% | ១,៤% | ២,០% | ៣,០% | ០,៨% |
| | មុន | -០,៥% | -០,៣% | ០,៥% | ១,០% | ១,១% | ០,០១% | ០,៤% | ០,៥% | ០,៥% | ០,៧% | -០,០៤% | ០,៧% | |
| ២០២៣ | ដូចគ្នាឆ្នាំមុន | ០,៣% | ២,២% | ០,៧% | ១,១% | ០,៥% | ០,១% | ១,៩% | ៣,២% | ៣,៨% | ៣,៩% | ២,៧% | ៣,២% | ២,២% |
| | មុន | ០,៧% | ០,៥% | ០,១% | ០,៥% | ០,២% | ០,៤% | ០,៤% | ០,៩% | ០,០២% | ០,១% | -០,៦% | ០,១% | |
| ២០២២ | ដូចគ្នាឆ្នាំមុន | ៤,១% | ៦,៣% | ៧,២% | ៧,៣% | ៧,២% | ៧,៨% | ៥,៤% | ៤,៩% | ៤,៤% | ៣,៦% | ៣,២% | ២,៩% | ៥,៣% |
| | មុន | ០,៦% | ១,២% | ១,៦% | ០,១% | ០,៨% | ០,៨% | ១-,៣% | -០,៥% | -០,៥% | -០,១% | ០,៥% | ១,១% | |

➢**អត្រាប្តូរប្រាក់:**

⇨ប្រាក់រៀលមានការឡើងថ្លៃ ១,៥% ធៀបនឹងប្រាក់ដុល្លារអាម៉េរិក ឡើងថ្លៃ៦,០%ធៀបនឹងប្រាក់ដុង ឡើងថ្លៃ ៤,២%ធៀបនឹងប្រាក់យ៉ន់ ឡើងថ្លៃ១,៧%ធៀបនឹងប្រាក់បាត និងឡើងថ្លៃ៧,៧%ធៀបនឹងប្រាក់អឺរ៉ូ ។ នាចុងឆ្នាំ ២០២៤ អត្រាប្តូរប្រាក់រៀល មានស្ថានភាពដូចខាងក្រោម:

| | |
|---|---|
| រៀល/ដុល្លារអាម៉េរិក : ៤ ០២៥៛/ដុល្លារ | រៀល/បាតថៃ : ១១៨៛/បាត |
| រៀល/ដុងវៀតណាម : ០,១៥៨៛/ដុង | រៀល/យ៉ន់ចិន : ៥៥១៛/យ៉ន់ |
| រៀល/អឺរ៉ូ : ៤ ១៩២៛/អឺរ៉ូ។ | |

## ២) ស្ថានភាពថវិកាជាតិ (តារាង ២)

យោងតាមស្ថិតិដែលឆ្លងរតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០២៤ អនុវត្តបាន ២៥ ៩៦២,២ ប៊ីលានរៀល (៦ ៤៥០ លានដុល្លារ) ត្រូវនឹង ៩៣% នៃផែនការ។ ក្នុងនោះចំណូលចរន្ត ២៥ ៥៦៧ ប៊ីលានរៀល (៦ ៣៥២ លានដុល្លារ) ត្រូវនឹង១០០% នៃផែនការ និងចំណូលមូលធន ៣៩៤,៨ប៊ីលានរៀល (៩៨,១ លានដុល្លារ) ត្រូវនឹង ១៥,៣% នៃផែនការ។ បើធៀបនឹងឆ្នាំ២០២៣ ចំណូលថវិកាជាតិថយចុះ ៣% ក្នុងនោះចំណូលចរន្តកើនឡើង ៤% ប៉ុន្តែចំណូលមូលធន ថយចុះ ៨២%។

⇨ចំណូលចរន្តកើនឡើង ជាចម្បងបណ្តាលមកពីចំណូលសារពើពន្ធកើនឡើង ២,៨% និងចំណូលមិនមែនសារពើពន្ធ កើនឡើង ១១,០%។

តារាង២.១. ចំណូលសារពើពន្ធ ឆ្នាំ២០២៤

| មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២៣ | មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២៣ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** * | ៩៦,១% | +២,៨% | **ចំណូលមិនមែនសារពើពន្ធ** * | ១៤២,៩% | +១១,០% |
| ✓**ពន្ធ និងអាករគយ** ** | — | +១៣,៧% | ✓កាស៊ីណូ | ១៤៧,២% | +៨៥,៦% |
| –ពន្ធគយ (របបនាំចូល) | — | -១,៨% | ✓ អាជ្ញាបណ្ណក្នុងស្រុក | ២៣៨,៦% | -២៣,០% |
| –អាករពិសេសលើរបបនាំចូល | — | +១៩,៧% | ✓ គ្រប់គ្រងនិងទិដ្ឋាការនាំចេញ | ៩៣,៣% | -១២,៨% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | — | +១៣,៩% | ✓ រុក្ខាប្រមាញ់ | ១០៧,២% | +១៣១,៩% |
| –អាករនាំចេញ | — | +១០៩,៤% | ✓សម្បទានរ៉ែ | ១៥០,២% | +៣៩,៨% |

| | | | | | |
|---|---|---|---|---|---|
| –អាករបន្ថែមលើតេលសិលា | — | +១៤,៦% | ✓អាកាសចរណ៍ស៊ីវិល | ២១៧,០% | +៧៤,៥% |
| ✓**ចំណូលពន្ធដារ** * * * | ៨៣,០% | -០,៦% | ✓ផលទុនទេសចរណ៍ | ២២៨,៦% | +៤៨,១% |
| –ពន្ធលើប្រាក់បៀវត្ស | ៨៧,២% | +៤,៣% | ✓ជួលរោងចក្រសហគ្រាសសម្ភារៈ | ១០៦,០% | +៦,១% |
| – ពន្ធលើប្រាក់ចំណូល | ៨២,៥% | +០,២% | ✓ប្រៃសណីយ៍និងទូរគមនាគមន៍ | ១១៤,៧% | +៦,៩% |
| – អាករលើតម្លៃបន្ថែម | ៨៧,១% | -៤,០% | | | |
| –អាករពិសេស | ៦១,៦% | -១,១% | | | |
| –ពន្ធថវិកាខេត្ត-រាជធានី | ៨៧,៥% | +១,៥% | | | |

* តួលេខរតនាគារជាតិ * *តួលេខអគ្គនាយកដ្ឋានគយនិងរដ្ឋាករ * * *តួលេខអគ្គនាយកដ្ឋានពន្ធដារ

ចំណាយថវិកាជាតិក្នុងឆ្នាំ២០២៤ អនុវត្តបាន ២៥ ៣១៦ ប៊ីលានរៀល(៦ ២៩០ លានដុល្លារ) ស្មើនឹង៧៣%នៃផែនការ ក្នុងនោះចំណាយចរន្ត ២១ ៥៣៧ប៊ីលានរៀល(៥ ៣៥០,៩ លានដុល្លារ) ស្មើនឹង៩១%នៃផែនការ និងចំណាយមូលធន ៣ ៧៧៩ ប៊ីលានរៀល(៩៣៩ លានដុល្លារ) ស្មើនឹង៣៥% នៃផែនការ។ បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិថយចុះ ៧% ក្នុងនោះចំណាយចរន្តកើនឡើង៧% ប៉ុន្តែចំណាយមូលធនថយចុះ ៤៧%។

ជាលទ្ធផល ថវិកាជាតិនាឆ្នាំ២០២៤មានអតិរេកចំនួន៦៤៦ ប៊ីលានរៀល(១៦១ លានដុល្លារអាម៉េរិក)។ គួរកត់សម្គាល់ថាតួលេខចំណាយមូលធនក្នុងតារាងទិន្នន័យឆ្លុះបញ្ចាំងតែចំណាយដែលឆ្លងរតនាគារជាតិតែប៉ុណ្ណោះ។

## ៣)ស្ថានភាពរូបិយវត្ថុ (តារាង ៣)

➢ សូចនាកររូបិយវត្ថុ : *M2* មានចំនួន ២២៧ ៤៤៥ ប៊ីលានរៀល កើនឡើង ១៨% ធៀបនឹងឆ្នាំ២០២៣។

**សមាសធាតុរូបិយវត្ថុខែធ្នូឆ្នាំ២០២៣** (%នៃរូបិយវត្ថុ *M2*)




**សមាសធាតុរូបិយវត្ថុខែធ្នូឆ្នាំ២០២៤**




☐ រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ (៛) ☐ ប្រាក់បញ្ញើចរន្ត ☐ ប្រាក់បញ្ញើផ្សេងទៀត

តារាង៣.១. កំណើនសូចនាកររូបិយវត្ថុ ២០២០-២០២៤ ធៀបនឹងឆ្នាំមុន

| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|
| *M2* | +១៥,៣% | +១៦,៣% | +៨,៣% | +១២,៥% | +១៧,៥% |
| *សមាមាត្រ M2 ក្នុងផសស* | +១២៥,២% | +១៣៦,០% | +១៤២,១% | +១៤៨,០% | +១៥៩,១% |
| *M1* | +៩,១% | +១៥,៣% | -៧,៧% | +៣,៨% | +១៥,៨% |
| *សមាមាត្រ M1 ក្នុងផសស* | ៣៥,៦% | ៣៨,៣% | ៣៤,២% | ៣២,៨% | ៣៤,៧% |
| រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ | +១៣,២% | +៨,៣% | -៣,១% | +៥,៩% | -២,៨% |

| | | | | | |
|---|---|---|---|---|---|
| ប្រាក់បញ្ញើចរន្ត | +៧,0% | +១៨,៩% | -៩,៩% | +២,៧% | +២៥,៨% |
| ប្រាក់បញ្ញើផ្សេងទៀត | +១៧,៩% | +១៦,៧% | +១៤,៦% | +១៥,៣% | +១៨,0% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +១៣,៩% | +១៥,0% | +៨,៤% | +១៣,0% | +១៩,៩% |

ក្នុងឆ្នាំ២០២៤ រូបិយវត្ថុទូទៅ*M2*មានចំនួនប្រហែល ១៥៩,១%នៃផសស ប៉ុន្តែ**សមមាត្រ***M1*ក្នុងផសស មានត្រឹមតែ ៣៤,៧% ប៉ុណ្ណោះ។

ទុនបំរុងជារូបិយប័ណ្ណបរទេសដុលមានចំនួន២២ ៥១១,៣ លានដុល្លារអាម៉េរិកកើនឡើង ១២,៦%ធៀបនឹងឆ្នាំមុន។

តារាង៣.២. អត្រាការប្រាក់ប្រចាំឆ្នាំ:

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ ២០២២* | *អត្រាឆ្នាំ ២០២៣* | *អត្រាឆ្នាំ ២០២៤* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,១% | ៦,៥% | ៥,១% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១០,៣% | ១១,0% | ១០,៩% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៥,៦% | ៦,១% | ៤,៧% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,៧% | ៩,៤% | ៩,២% |
| កម្ចីជារៀលនៅអិល អូ អិល ស៊ី | ១៨,0% | ១៧,៤% | ១៦,១% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៦% | ១៦,៨% | ១៧,៣% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម រ៉ែនិងថាមពល សំណង់ ការចុះបញ្ជីនិងលុបចេញពីបញ្ជីពាណិជ្ជកម្ម ការងារ វិនិយោគ សេវាកម្មទំនិញឆ្លងកាត់តាមកំពង់ផែ ការចុះបញ្ជីនិងចរាចរណ៍ប្រៃសណីយ៍និងទូរគមនាគមន៍ អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ ទេសចរណ៍ និងបរិស្ថាន (តារាងទី៤)

➢ ***កសិកម្ម:***

⇨ផ្ទៃដីដាំដំណាំ ស្រូវឆ្នាំ២០២៤ មានចំនួន៣ ៨៥៦,0 ពាន់ហិកតា កើនឡើង៨,៧% ធៀបនឹងឆ្នាំ២០២៣។

⇨ក្នុងឆ្នាំ២០២៤ ផលិតផលកៅស៊ូមានចំនួន៤០៧,២ពាន់តោន កើនឡើង ៣,៩% ធៀបនឹងឆ្នាំ២០២៣។ ផ្ទៃដីចៀរជ័រមានចំនួន៣៣០,៣ ពាន់ហិកតាកើនឡើង៣,១%ធៀបនឹងឆ្នាំ២០២៣ និងផ្ទៃដីដាំដុះសរុបមាន ៤២៥,៤ ពាន់ហិចតា កើនឡើង៤,៥%ធៀបនឹងឆ្នាំ២០២៣។

⇨ ផលិតផលជលផលឆ្នាំ២០២៤ មានចំនួន៩២៦,៩ ពាន់តោនមានការកើនឡើង៧,0% ធៀបនឹងឆ្នាំ២០២៣។

➢ ***ឧស្សាហកម្ម***

⇨ចំនួនរោងចក្រសរុបដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្មមានចំនួន២ ៤២៥ រោងចក្រកើនឡើង១៤,១% ធៀបនឹងឆ្នាំ២០២៣។

⇨ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

| *ប្រភេទ* | *ចំនួន :២០២៤* | *ចំនួន:២០២៣* | %∆ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ២ ៤២៥ | ២ ១២៥ | ១៤,១% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ៣២៦ | ២៤១ | ៣៥,៣% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១ ២៩២ | ១ ៤០៦ | -៨,១% |
| ឧស្សាហកម្មធនតូច និងសិប្បកម្ម (បន្ត) | ១ ៣៣៨ | ១ ៤០៦ | -៤,៨% |

➢ ***រ៉ែនិងថាមពល:***

ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន១៩ ៥២៧,៣ GWh កើនឡើង ១៧,៧% ធៀបនឹងឆ្នាំ២០២៣។ ក្នុងនោះ៖

- វារីអគ្គិសនីចំនួន ៧ ២២៨ GWh ថយចុះ ១,៤% ធៀបនឹងឆ្នាំ២០២៣ (៣៧% នៃការផ្គត់ផ្គង់សរុប)
- ធ្យូងថ្មចំនួន៩ ២០៩ GWh កើនឡើង ២០% ធៀបនឹងឆ្នាំ២០២៣ (៤៧%)
- ថាមពលពន្លឺព្រះអាទិត្យ (Solar) ចំនួន១ ០៤០ GWh កើនឡើង ៣០% ធៀបនឹងឆ្នាំ២០២៣ (៥%)
- នាំចូលពីប្រទេសជិតខាងចំនួន១ ៤៥៥ GWh កើនឡើង ១១៣% ធៀបនឹងឆ្នាំ២០២៣ (៨%)
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀត ៥៩៥,៨ GWh កើនឡើង ៤២៤% ធៀបនឹងឆ្នាំ២០២៣ (៣១%)។

ផលិតកម្មស៊ីម៉ងត៍ ក្នុងឆ្នាំ២០២៤ មានចំនួន៨ ៤៣៤,៣ ពាន់តោនមានការកើនឡើង១២,១%ធៀបនឹងឆ្នាំ២០២៣។

➢ **សំណង់ (ការអនុញ្ញាត):**

សំណង់អនុញ្ញាតឱ្យសាងសង់មានចំនួន១៣ ៥៣៦,៨ ពាន់ម² មានការកើនឡើង ៣,១% ធៀបនឹងឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៥ ៧៤១,៨ លានដុល្លារមានការកើនឡើង៥,១% បើធៀបនឹងឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

| *ប្រភេទសំណង់* | ពាន់ម² :២០២៤ | ពាន់ម² :២០២៣ | % Δ |
|---|---|---|---|
| លំនៅឋាន | ៤ ២៧៦,១ | ៦ ៩៧៨,៧ | -៣៨,៧% |
| ឧស្សាហកម្ម | ៥ ២៧៧,៩ | ៣ ២២០,៨ | ៦៣,៩% |
| ពាណិជ្ជកម្ម | ២ ៧៥៧,៥ | ២ ១១៨,៣ | ៣០,២% |
| ទេសចរណ៍ | ៤៣៥,៦ | ២៥៩,៣ | ៦៨,០% |
| អនុញ្ញាតសរុប | ១៣ ៥៣៦,៨ | ១៣ ១៣១,៨ | |

ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមឆ្នាំ ២០២៤ នេះគឺឧស្សាហកម្ម (៣៩%) និងសំណង់លំនៅឋាន (៣២%)។

➢ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី**

| *ប្រភេទ* | *២០២៤ (ចំនួន)* | *២០២៣ (ចំនួន)* | %Δ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៥ ២០១ | ៤ ៧១៩ | ១០,២% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១ ២១៤ | ៩៤១ | ២៩,០% |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ៥ ៤២៦ | ៥ ៧២២ | -៥,២% |
| ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | ៦៤ | ១១៨ | -៤៥,៨% |
| ក្នុងនោះ: លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ២៤ | ៧៤ | -៦៧,៦% |

➢ **ការងារ**

| *ប្រភេទ* | ២០២៤ (នាក់) | ២០២៣ (នាក់) | %Δ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៥០ ៤៩៤ | ៣០ ៨៩៧ | ៦៣,៤% |
| អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ៣៣៨ ៩៧៤ | ៤០៤ ១៦៥ | -១៦,១% |

| | | | |
|---|---|---|---|
| អ្នកទទួលបានការងារក្នុងប្រទេស | ២៩៤ ១១២ | ៣៤៣ ៦៩៨ | -១៤,៤% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤៤ ៨៦២ | ៦០ ៤៦៧ | -២៥,៨% |

➢ ***វិនិយោគ:****គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក.*

| *ប្រភេទ* | *២០២៤* | *២០២៣* | %∆ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៦ ៨៧២,៤ | ៤ ៩២៧,៥ | ៣៩,៥% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១២០,៥ | ៣២៨,៦ | -៦៣,៣% |
| វិស័យឧស្សាហកម្ម | ៤ ៧៥៤,០ | ២ ២៥៩,៨ | ១១០,៤% |
| (ក្នុងនោះក្នុងតំបន់សេដ្ឋកិច្ចពិសេស) | ២ ៩៩៨,២ | ៧៤៤,៤ | ៣០២,៧% |
| វិស័យទេសចរណ៍ | ៧៣៨,៩ | ១៥៣,៣ | ៣៨១,៩% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១ ២៥៨,៩ | ២ ១៨៥,៩ | -៤២,៤% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ៤១៤ | ២៦៨ | ៥៤,៥% |
| **ចំនួនពលករ (ពាន់នាក់)** | ៣២៤,៦ | ៣០៧,៦ | ៥,៦% |

➢**សេវាកម្មនិងទេសចរណ៍:**

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ)មានចំនួន១៣ ៩៩៥,២ ពាន់តោនថយចុះ០,៥%ធៀបនឹងឆ្នាំ២០២៣។ ក្នុងនោះ:

| *ប្រភេទ* | ២០២៤ (ពាន់តោន) | ២០២៣ (ពាន់តោន) | *%∆* |
|---|---|---|---|
| កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ៩ ៦៥៩,២ | ៩ ៨០២,៦ | -១,៥% |
| កំពង់ផែស្វយ័តភ្នំពេញ | ៤ ៣៣៦,០ | ៤ ២៦៦,០ | +១,៦% |
| កុងតឺន័រឆ្លងកាត់កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ១ ០២០,២ | ៧៨៩,៣ | +២៩,៣% |
| កុងតឺន័រឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ | ៤៧៨,៣ | ៣៩២,០ | +២២,០% |

➢**ការចុះបញ្ជី និងចរាចរណ៍**

ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| *ប្រភេទ* | ២០២៤ (ចំនួន) | ២០២៣ (ចំនួន) | *%∆* |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៣៤៣,២ | ៣០៥,៨ | ១២,៣% |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ៥១,៦ | ៥៧,៨ | -១០,៧% |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ២ ៨៨៩ | ៣ ២៩៦ | -១២,៣% |

➢**ប្រៃសណីយ៍និងទូរគមនាគមន៍**

| *ប្រភេទ* | ២០២៤ | ២០២៣ | *%∆* |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៧៣,១ | ១៤១,៩ | ២១,៩% |
| ក្នុងនោះទទួល | ៦០,៤ | ៤១,០ | ៤៧,២% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៤៣៣,៩ | ៤០៨,២ | |

| | | | |
|---|---|---|---|
| ក្នុងនោះទទួល | ២២៨,៥ | ២០៨,៦ | ៦,៣% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ៥ ១៤២,៥ | ៥ ៦៤៧,៦ | ៩,៥% |
| ក្នុងនោះហៅចូល | ១ ៩០១,៤ | ១ ៨៩៩,១ | -៨,៩% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១៧ ៨៧២,៦ | ១៤ ៩៣១,៩ | ០,១% |
| ក្នុងនោះហៅចូល | ១៧ ៧៨៣,៦ | ១៤ ៧៣១,១ | ១៩,៧% |
| | | | ២០,៧% |

➢**អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍**

| *ប្រភេទ* | ២០២៤ (ពាន់នាក់) | ២០២៣ (ពាន់នាក់) | %Δ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១២៤,២ | ៩៥,៩ | ២៩,៥% |
| ភ្ញៀវទេសចរបរទេសទិញបណ្ណទស្សនាអង្គរ | ១ ០២៣,៧ | ៧៩៨,១ | ២៨,៣% |
| ភ្ញៀវទេសចរបរទេសចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ១៥,៣ | ៩,១ | ៦៧,៨% |
| ភ្ញៀវទេសចរបរទេសចូលទស្សនា រមណីយដ្ឋានកោះកេរ | ២១,៩ | ១៥,២ | ៤៤,៧% |
| ភ្ញៀវទេសចរបរទេសចូលទស្សនា រមណីយដ្ឋានសំបូរព្រៃគុក | ១៥,៥ | ១១,០ | ៤១,០% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៣១១,៦ | ១៧០,៦ | ៨២,៦% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥ ៩២៤,៨ | ៤ ៦១១,៦ | ២៨,៥% |
| ទំនិញដឹកជញ្ជូនតាមផ្លូវអាកាស | ៧៧,៩ | ៥៥,៧ | ៣៩,៨% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ១ ៨៤៥,៥ | ១ ៨១៩,៥ | ១,៤% |
| ចំនួនទេសចរផ្ទៃក្នុង | ២៦ ៥០៥,៨ | ២១ ០១១,៣ | ២៦,២% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ៦ ៧០០,១ | ៥ ៤៥៣,២ | ២២,៩% |
| ✓តាមផ្លូវអាកាស | ២ ៣៩៦,៩ | ១ ៨៦៦,២ | ២៨,៤% |
| ✓ តាមផ្លូវគោក និងទឹក | ៤ ៣០៣,២ | ៣ ៥៨៧,០ | ២០,០% |
| កម្រិតគុណភាពខ្យល់នៅកម្ពុជា(PM2.5) | ១៧ μg/m$^3$ | ១២,៣ μg/m$^3$ | ៣៨,២% |

## ៥)ស្ថានភាពពាណិជ្ជកម្ម (តារាង៥)

▪យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០២៤ មានចំនួន១១១ ៣៥១,១ប៊ីលានរៀល (គិតជាដុល្លារអាម៉េរិក២៧ ៦៦៤,៩ លានដុល្លារ) កើនឡើង១៨,២% បើធៀបនឹងឆ្នាំ ២០២៣ក្នុងនោះ ៖

| មានការកើនឡើង | មានការថយចុះ |
|---|---|
| ប្រេងឥន្ធនៈ +១៩,១% | ស៊ីម៉ងត៍ -១៨,៣% |
| ប្រេងសាំង +១៥,៥% | រថយន្តដឹកជញ្ជូន -១៣,៤% |
| | នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម -៣,៦% |

| | |
|---|---|
| ប្រេងម៉ាស៊ូត +១៤,៧% | អង្ករ -៤៧,៦% |
| ឧស្ម័ន+១៤,២% | ផ្លែឈើ និងបន្លែ -៤,១% |
| ដែកសំណង់ +៦៩,៥% | |
| ប្រេងសាំងយន្តហោះ +២៨,៤% | |
| ប្រេងខ្មៅ+៨០៤,២% | |
| រថយន្តសរុប +១២,១% | |
| រថយន្តទេសចរណ៍ +២០,៩% | |
| ត្រាក់ទ័រ និងគោយន្ត +៦៧,១% | |
| ស្រូវសាឡី +៣០,៦% | |
| ជីកសិកម្ម +២៣,៩% | |
| ថ្នាំកសិកម្ម +៣១,៩% | |
| នាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +១១,០% | |

▪**ការនាំចេញ**ឆ្នាំ២០២៤មានចំនួន៩៦ ៥៧១,៤ ប៊ីលានរៀល(គិតជាដុល្លារអាម៉េរិក២៣ ៩៩២,៩ លានដុល្លារ)ស្មើនឹង ៨៦,៧%នៃការនាំចូល មានការកើនឡើង១០,៩% ធៀបនឹងឆ្នាំ២០២៣ក្នុងនោះ ៖

| *ទំនិញ* | %Δ ធៀបនឹង-២០២៣ | *ទំនិញ* | %Δ ធៀបនឹង-២០២៣ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៨២,១% | ផលិតផលនេសាទ | +៨,២% |
| វាយនភណ្ឌនិងស្បែកជើង | +២០,៩% | កៅស៊ូ | -១០,៩% |
| អង្ករ | -២,៨% | ខ្សាច់ | +១៥០,២% |

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ឆែម គាតរិទ្ធី








ក្រុមបច្ចេកទេសរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន

អាសយដ្ឋាន: អគារមិត្តភាព លេខ៤១ មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ: ០៨៥ ៧៧៧ ៩៤០ / ០១២ ៦៦២ ៣១៦ ទូរសារ: ០២៣ ២២១ ៩៤០

Email: chyanit168@gmail.com / mamsarith@yahoo.com